# ប្រាសាទសំបូរ (ប្រាង្គ N7)

ដូចដែលធ្លាប់ដឹងច្រើនមកហើយថា នៅក្រុមប្រាសាទសំបូរ (ក្រុមខាងជើង) នៃតំបន់ប្រាសាទសំបូរព្រៃគុក មានប្រាសាទរាងប្រាំបីជ្រុងតែមួយប៉ុណ្ណោះ ដែលលោក Henri Parmentier ចុះបញ្ជីប្រាង្គ N7។ ផ្ទុយពីនៅក្រុមប្រាសាទយាយព័ន្ធ ដែលមានប្រាសាទរាងប្រាំបីជ្រុងរហូតដល់ ៦។ ប្រាង្គ N7 នេះ ជាប្រាសាទរណបស្ថិតនៅទិសនិរតីនៃប្រាង្គសំខាន់ (N1) និងស្ថិតនៅក្នុងបរិវេណកំពែងទី១នៃក្រុមប្រាសាទសំបូរ។ តើប្រាង្គ N7 មានប្រវត្តិ និងលក្ខណៈដូចម្ដេចខ្លះ?

ប្រាសាទសំបូរ (ប្រាង្គ N7) ជាប្រភេទសំណង់ទោល សាងឡើងអំពីឥដ្ឋ មានរាងប្រាំបីជ្រុង ដែលប្រវែងជ្រុងនីមួយៗពុំស្មើគ្នានោះទេ។ យើងមិនអាចពន្យល់ឱ្យបានច្បាស់លាស់ថា ហេតុអ្វីស្ថាបត្យករពុំកសាងជ្រុងនីមួយៗឱ្យស្មើគ្នានោះទេ។ ប៉ុន្តែ យើងអាចសន្និដ្ឋានថា ការធ្វើបែបនេះទំនងមកពីគេយល់ថា *"មនុស្សមិនមែនជាទេពឡើយ ម៉្លោះហើយសំណង់ដែលមនុស្សកសាងសម្រាប់ទេព មិនអាចត្រូវតែតខ្ចោះនោះឡើយ"*។ ផ្នែកខាងលើ ឬផ្នែកកំពូលរបស់ប្រាង្គនេះ គេសង់ឡើងជាថ្នាក់ៗ ដោយបង្រួមខ្នាតពីធំទៅតូចចាប់ពីផ្នែកខាងក្រោមទៅលើកំពូលបញ្ចប់ដោយការប្រក់ដំបូលមានរាងកោងដូចទូក ពោល គឺមានលំនាំស្រដៀងសំណង់នៅឥណ្ឌាខាងជើង (វលភី) និងឥណ្ឌាខាងត្បូង (សាលា)។ នៅតាមថ្នាក់ទាំងអស់នៃដំបូល គេលម្អដោយក្បាច់គុឌុ (ចម្លាក់មានរាងដូចកូនបង្អួច) សរុបចំនួន ២៤ គុឌុ ដែលនៅខាងក្នុងគុឌុមានលម្អជារុក្ខជាតិ។ ចម្លាក់គុឌុនៅលើផ្នែកដំបូលប្រាសាទនេះ មានលក្ខណៈខុសពីចម្លាក់គុឌុដែលរកឃើញនៅក្រុមប្រាសាទយាយព័ន្ធ (ក្រុមខាងត្បូង) ដែលជាទូទៅមានចម្លាក់មនុស្សឬទេពនៅខាងក្នុង។ ប៉ុន្តែ ចម្លាក់គុឌុដែលមានចម្លាក់រុក្ខជាតិនៅខាងក្នុងបែបនេះ យើងច្រើនឃើញនៅក្នុងក្រុមប្រាសាទសំបូរ។ ហេតុផលនេះទំនងស្ដែងឱ្យឃើញថា ចម្លាក់គុឌុដែលខ្មែរទទួលឥទ្ធិពលពីសិល្បៈឥណ្ឌាខាងត្បូងសម័យគុប្ត (ស.វ.ទី៤-៧) បានវិវឌ្ឍរូបរាងខ្លះៗ និងបន្តវិវឌ្ឍទៅជាក្បាច់កញ្ចាំងដែលជាលក្ខណៈសិល្បៈខ្មែរផ្ទាល់ខ្លួននៅសម័យអង្គរ។ ខឿនខាងក្រោមរៀបជាថ្នាក់ៗលម្អដោយក្បាច់សសរស្ដម្ភមានរូបក្អមទឹក (ស្តម្ភ-កុម្ភៈ) និងក្បាច់រុក្ខជាតិ។

ប្រាង្គ N7 មានច្រកចូលនៅទិសខាងកើត និងនៅចំពីមុខប្រាសាទមានជើងទម្រងមានរាងប្រាំបីជ្រុងដូចគ្នា (N7-1) តែគេមិនដឹងច្បាស់ថា ជើងទម្រដែលមានរាងប្រាំបីជ្រុងនោះកាលពីមុនមកគេតម្កល់បដិមារូបសត្វ ឬទេវរូបអង្គណាមួយឡើយ។ លក្ខណៈបែបនេះ គេមិនធ្លាប់ឃើញមានតំបន់ប្រាសាទសំបូរព្រៃគុកឡើយ។ នៅច្រកចូលខាងកើតនេះ មានផ្តែរទ្វារមួយធ្វើអំពីថ្មភក់

អត្ថបទដោយៈ ម៉ង់ រ៉ាលី

ដែលចម្លាក់ជាទូទៅសឹងតែដូចផ្តែរទ្វារផ្សេងទៀតនៅក្នុងតំបន់ ពោល គឺជាផ្តែរទ្វារអាចចាត់បញ្ចូលជាសិល្បៈរចនាបថសំបូរព្រៃគុក ដោយមានចម្លាក់សត្វមករនៅចុងសងខាងបែរមុខចូលក្នុង ក្បាច់បន្ទាត់ធ្នូមានរាងកោង និងមានចម្លាក់ព្រះឥន្ទ្រគង់នៅលើដំរីឰរ៉ាវតនៅចំកណ្តាល អមដោយចម្លាក់ព្រះមរុតជិះសេះនៅសងខាង។ ផ្តែរទ្វារនេះ សព្វថ្ងៃគេយកទៅតម្កល់ទុកនៅអគារសាលពិព័រណ៌សំបូរព្រៃគុក ដែលស្ថិតនៅខាងកើតប្រាង្គ N7 ចម្ងាយប្រមាណ ១៥០ ម៉ែត្រ។ កាន់តែគួរឱ្យចាប់អារម្មណ៍ខ្លាំងជាងគេ គឺនៅតាមជញ្ជាំងប្រាសាទ (៧ជ្រុង) សុទ្ធសឹងមានលម្អជាចម្លាក់វិមានអណ្តែតនៅប្រាង្គ N7 ដែលចម្លាក់នីមួយៗនៅរក្សារូបរាងបានល្អប្រសើរជាងប្រាង្គផ្សេងៗទៀតនៅក្នុងក្រុម។ គ្រប់វិមានអណ្តែតទាំងអស់ មានលម្អចម្លាក់រូបសត្វផ្សេងៗ (តោ សេះ គ្រុឌ) ត្រដាងស្វាបទ្រពីក្រោមវិមាន ហាក់បីដូចជាវិមានកំពុងហោះហើរនៅលើអាកាសពិតៗដូច្នោះដែរ។ ទោះបីរូបចម្លាក់មានសភាពច្បាស់ល្អយ៉ាងណាក្តី អ្នកស្រាវជ្រាវកន្លងមកពុំអាចកត់សម្គាល់ថា រូបភាពចម្លាក់ទាំងនោះតំណាងឱ្យទេពណាមួយឱ្យប្រាកដឡើយ។ ក្នុងចំណោមនោះ មានចម្លាក់ទេពមួយដែលស្ថិតនៅចំកណ្តាលនៃវិមានអណ្តែតទិសឦសាន លោក ចិន្ត ច័ន្ទរតនា សន្និដ្ឋានថាជារូបភាពព្រះអវលោកិតេស្វរ (លោកេស្វរ)។ លោកសន្និដ្ឋានដូច្នេះ ដោយយោងទៅលើកាយវិការ និងកេតនភណ្ឌនៅក្នុងព្រះហស្តរបស់ទ្រង់ស្រដៀងបដិមាព្រះអវលោកិតេស្វរធ្វើអំពីសំរិទ្ធិមួយ ដែលកំពុងតម្កល់នៅសារមន្ទីរជាតិភ្នំពេញ។ ម្យ៉ាងវិញទៀត លោកយល់ថា វាអាចទៅរួច ដែលប្រាសាទព្រហ្មញ្ញសាសនាឆ្លាក់រូបព្រះពោធិសត្វនៃព្រះពុទ្ធសាសនានៅតាមជញ្ជាំង ដ្បិតលោកបានយោងទៅលើកំណត់ហេតុរបស់អ្នកធ្វើធម្មយាត្រាចិនឈ្មោះ "យី-ស៊ីង" (Yi-Tsing) ដែលបានរៀបរាប់ថា "មនុស្សនៅហ្វូណនបានគោរពបូជាព្រះជាម្ចាស់ជាច្រើននិងបន្ទាប់មកច្បាប់របស់ព្រះពុទ្ធក៏រីកចម្រើនឡើង"។ ការសន្និដ្ឋាននេះ ក៏ពុំមានអ្វីរឹងមាំនោះឡើយ ព្រោះជាទូទៅនៅលើផ្តួងសក់ព្រះពោធិសត្វអវលោកិតេស្វរ តែងមានរូបព្រះពុទ្ធអាមិតភៈនៅលើផ្តួងសក់ ប៉ុន្តែចម្លាក់ទេពនៅជញ្ជាំងប្រាសាទសំបូរ (ប្រាង្គ N7) ពុំមានឆ្លាក់រូបព្រះពុទ្ធអាមិតភៈនៅលើផ្តួងសក់ឡើយ។

នៅផ្នែកខាងក្នុងប្រាសាទវិញ គេរៀបជាបន្ទប់រាងប្រាំបីជ្រុង ដោយមានយ៉ចូលពីច្រកចូលខាងកើត។ នៅទ្វារខាងកើតផ្នែកខាងក្នុង គេធ្វើជារាងសាជីទ្រដោយបន្ទះថ្មភក់ដើម្បីសម្រាលទម្ងន់ដូចប្រាង្គ N1 ដែរ។ នៅតាមជ្រុងជញ្ជាំងខាងក្នុង មានរៀបថ្មភក់រាងដូចកំណាត់ឈើជ្រុងភ្ជាប់ជាមួយឥដ្ឋដើម្បីតម្រៀបធ្វើជាពិតាន (ប្រក់ក្រណាត់គ្របពីលើទេព) ឬអាចជាបច្ចេកទេស

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

*មួយសម្រាប់ទប់ឥដ្ឋប្រាសាទឱ្យកាន់តែរឹងមាំក៏ថាបាន។ នៅខាងក្នុងគភ៌គ្រឹះប្រាសាទ មានជើងទម្រមួយរាងមូលផ្គុំឡើងដោយថ្មភក់បួនជាន់ ដោយមានថ្មភក់រាងមូលជាកម្រាលទ្រពីក្រោម។ ជើងទម្រដែលមានការផ្គុំគ្នាដោយថ្មភក់ជាបួនជាន់បែបនេះ គឺជាលក្ខណៈជាទូទៅដែលយើងតែងឃើញនៅស.វ.ទី៧ ផ្ទុយពីជើងទម្រនៅសម័យអង្គរគេយកថ្មភក់តែមួយមកឆ្លាក់ចេញជារាងជើងទម្រតែម្តង។ ម៉្យាងហើយ យើងមិនដឹងព័ត៌មានថា ជើងទម្ររាងមូលនេះកាលពីដើមមកតម្កល់ទេវរូបណាមួយនោះឡើយ។ ប៉ុន្តែ បើយោងទៅតាមការរៀបរាប់របស់លោក* Adhemar Leclère *ដែលជាជនជាតិបារាំងបានទៅដល់តំបន់ប្រាសាទសំបូរព្រៃគុកដំបូងគេ (ឆ្នាំ១៨៩១) បានបញ្ជាក់ថា លោកបានប្រទះឃើញបដិមាមួយដែលមានដងខ្លួនជាមនុស្ស និងក្បាលជាសេះ ស្ថិតនៅក្នុងសភាពបែកបាក់ស្ថិតនៅក្បែរជើងទម្រ ដោយលោកបានហៅរូបនោះថា* ***"ព្រះសេដ្ឋីសួគ៌"*** *ដែលជាមេកើយរបស់ព្រះកុវេរ (ព្រះនៃទ្រព្យសម្បត្តិ)។ ប្រាំឆ្នាំក្រោយមក លោកបានបញ្ជូនបដិមាដ៏ស្រស់ស្អាតនេះទៅដាក់តាំងបង្ហាញនៅសារមន្ទីរខ្មែរក្នុងទីក្រុងត្រូកាដេរ៉ូ ប្រទេសបារាំង ហើយនៅឆ្នាំ១៩២៧ គេបានបញ្ជូនរូបនេះទៅដាក់តាំងបង្ហាញនៅសារមន្ទីរជាតិហ្គីមេ នៅទីក្រុងប៉ារីស ប្រទេសបារាំង។ សំណេររបស់លោកត្រង់ចំណុចនេះបានបញ្ជាក់ឱ្យឃើញថា ព្រះបដិមាដែលលោកហៅថា "ព្រះសេដ្ឋីសួគ៌" នេះ មិនមែនរកឃើញនៅលើជើងទម្ររាងមូលដែលយើងកំពុងឃើញបច្ចុប្បន្ននោះឡើយ។ នៅទសវត្សរ៍ ១៩២០ លោក* Victor Goloubew *បានសន្និដ្ឋានថា បដិមានេះជា* ***"ព្រះលោកេសូរ-វាលហ"*** *។ ប៉ុន្តែ អ្នកស្រាវជ្រាវសម័យក្រោយយល់ថា បដិមានេះគឺជាអវតាររបស់ព្រះវិស្ណុដែលបានសម្លាប់អសុរពីរនាក់ (មធុ និងកៃដភ) ដើម្បីដណ្តើមគម្ពីរវេទពីអសុរទាំងពីរនេះថ្វាយដល់ព្រះព្រហ្មវិញដើម្បីគ្រប់គ្រងថែរក្សាលោក ហើយអវតារនេះមានព្រះនាមថា* ***"ហយគ្រីវ"*** *។ នៅក្នុងឆ្នាំ១៩៣៤ លោក* Pierre Dupont *បានចាត់បញ្ចូលបដិមាហយគ្រីវនេះ ជាសិល្បៈរចនាបថព្រះគោ នាចុងស.វ.ទី៩ តែក្រោយមក លោក* Jean Boisselier *យល់ថា បដិមានេះជាទម្រង់សិល្បៈរចនាបថប្រែរូបនៅពាក់កណ្តាលស.វ.ទី១០ ក្នុងរជ្ជកាលព្រះបាទស្រីរាជេន្ទ្រវរ្ម័ន (គ.ស.៩៤៤-៩៦៧) ពោល គឺស្របទៅនឹងកាលបរិច្ឆេទសិលាចារឹកដែលរកឃើញនៅក្នុងក្រុមប្រាសាទសំបូរ ដែលបញ្ជាក់ឱ្យឃើញថា ប្រាសាទសំបូរ ប្រាង្គ* N7 *ទំនងកសាងឡើងនៅស.វ.ទី៧ ក្នុងរវាងរជ្ជកាលព្រះបាទស្រីឦសានវរ្ម័ន (គ.ស.៦១៦-៦៣៧) ហើយបានជួសជុល ឬកសាងបន្ថែម និងដាក់តម្កល់បដិមាព្រះហយគ្រីវនៅក្នុងប្រាសាទនាស.វ.ទី១០ រជ្ជកាលព្រះបាទ*

*អត្ថបទដោយ៖ ម៉ង់ វ៉ាលី*

ស្រីរាជេន្ទ្រវរ្ម័ន។ ចម្ងល់នៅត្រង់ចំណុចនេះគឺ តើជើងទម្រទាងមូលដែលយើងឃើញបច្ចុប្បន្ននៅក្នុងប្រាសាទនេះតម្កល់ទេវរូបណាមួយ? រីឯបដិមាព្រះហយគ្រីវដែលលោក Adhemar Leclère អះអាងថាបានរកឃើញនៅក្នុងប្រាសាទដែរនោះតម្កល់នៅលើជើងទម្រណាមួយ? ឬតម្កល់នៅត្រង់ចំណុចណាឱ្យពិតប្រាកដ? ឬមួយតម្កល់លើជើងទម្រទាងប្រាំបីជ្រុងដែលគេឃើញនៅខាងមុខប្រាសាទ?

សរុបជារួមមក ប្រាសាទសំបូរ ប្រាង្គ N7 ជាប្រាសាទរណបដែលមានរាងប្រាំបីជ្រុង និងប្លែកពីប្រាង្គដទៃទៀតនៅក្នុងក្រុមប្រាសាទសំបូរ (ក្រុមខាងជើង) ដែលទំនងកសាងឡើងនៅរវាង ស.វ.ទី៧ (រជ្ជកាលព្រះបាទស្រីឦសានវរ្ម័ន) និងអាចជួសជុលឬសង់បន្ថែមនៅស.វ.ទី១០ (រជ្ជកាលព្រះបាទស្រីរាជេន្ទ្រវរ្ម័ន)។ យើងមិនអាចពន្យល់មូលហេតុឱ្យបានជាក់លាក់ថា ហេតុអ្វីបានជាក្នុងមួយក្រុមមានតែប្រាង្គនេះមួយគត់ដែលមានរាងប្រាំបីជ្រុងនោះទេ ព្រោះព័ត៌មានផ្នែកសិលាចារឹក និងបុរាណវិទ្យាមិនមានភស្តុតាងណាមួយដែលអាចជាភស្តុតាងបកស្រាយចម្ងល់នេះបានឡើយ។ ប៉ុន្តែ ដោយហេតុថា ប្រាង្គនេះធ្លាប់រកឃើញបដិមាព្រះហយគ្រីវ ដែលជាអវតារមួយរបស់ព្រះវិស្ណុ យើងអាចសន្និដ្ឋានបឋមថា ប្រាង្គនេះមានជាប់ពាក់ព័ន្ធជាមួយព្រះវិស្ណុ ព្រោះជាទូទៅព្រះវិស្ណុជាប់ទាក់ទងនឹងលេខ ៨ ដែលជាលេខតំណាងឱ្យនិម្មិតសញ្ញាគ្មានទីបញ្ចប់របស់ព្រះវិស្ណុ និងតំណាងឱ្យការកើតជាថ្មី ការបង្កើតថ្មី និងការរក្សាលំនឹងលោកទាំងមូល។ ម្យ៉ាងវិញទៀត ដោយសារព្រះហយគ្រីវជាតួអង្គបង្ក្រាបអសុរទាំងពីរ (មធុ និងកៃដភ) ដើម្បីដណ្តើមគម្ពីរវេទថ្វាយព្រះព្រហ្មវិញ យើងអាចទាញសេចក្តីសន្និដ្ឋានបឋមមួយទៀតថា ជើងទម្រទាងមូលតម្កល់នៅក្នុងប្រាសាទដែលកសាងឡើងតាំងពីស.វ.ទី៧មកនោះ (ប្រាសាទនេះកសាងឡើងនៅស.វ.ទី៧) ទំនងជាជាប់ពាក់ព័ន្ធជាមួយព្រះព្រហ្មដូចគ្នាដែរ ពោល ប្រហែលជាអាចតម្កល់ព្រះព្រហ្មផងក៏មិនដឹង ព្រោះព្រះអង្គប្រសូត្រនៅលើផ្កាឈូកមានរាងមូល ដែលជានិម្មិតរូបតំណាងឱ្យការបង្កើតលោក និងភាពគ្មានទីបញ្ចប់នៃលោក។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

# ឯកសារពិគ្រោះ

**ម៉ង់ វ៉ាលី** ២០២១, *កំពង់ធំ ប្រវត្តិសាស្ត្រ និងប្រាសាទបុរាណ*, ភ្នំពេញ។

**ម៉ង់ វ៉ាលី, ហ៊ិន សោភ័ណ, កុំ រតនៈពិសិដ្ឋ** ២០១៨, តំបន់ប្រាសាទសំបូរព្រៃគុក, កំពង់ធំ។

**ស្រី សមប៊ុនណារ៉ុង** ២០២៤, *សាកល្បងសិក្សាប្រាសាទរាងប្រាំបីជ្រុងនៅសំបូរព្រៃគុក*, សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យា, ជំនាន់ទី៣២ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ។

**Baptiste, P. & Zéphir, T.** 2008. *L'Art Khmer dans les collections du musée Guimet,* Paris.

**Boisselier, J.** 1966, "*Asie du Sud-Est, Le Cambodge*", Tome I, Paris.

**CHEN Chanratana** 2005-2006. Etudes des palais volants dans l'art Khmer préangkorien, Diplôme de Master de recherché Histoire et Archéologie de l'Asie de Sud-est Année, Universite Pariss III-Sorbonne nouvelle UFR orient et Monde Arabe, Paris.

**Coedès, G.** 1952. *Inscription du Cambodge,* Vol. IV, Hanoi.

**Dupont, P.** 1934, *Musée Guimet, catalogue des collections indochinoises,* Extrait du *Bulletin de la Commission archéologique de l'Indochine, années* 1931-1934, Imprimerie nationale et éditions Ernest Leroux, Paris.

**Lajonquière, L.**1902, *Inventaire descriptive des monuments du Cambodge*, Tome I, Paris.

**Leclère, A.** 1894, 'Fouilles de Kompong-Soay (Cambodge), communication faite par M. Adhémar [sic] Leclère, Résident de France au Cambodge. Séance du 19 octobre 1894. No. XXVII, Académie des Inscriptions et Belles-Lettres – Comptes Rendus des séances de l'année 1894, quatrième série, t. XXII, Imprimerie nationale, pp. 367-378, Paris.

**Parmentier, H.** 1927. *L'art Khmère primitif*, Tome I & II, Paris.

AMS អរិយធម៌ខ្មែរ KHMER CIVILIZATION



រូបលេខ១៖ ប្រាសាទសំបូរ ប្រាង្គ N7 (មើលពីមុខអាគ្នេយ៍)



រូបលេខ២៖ ប្រាសាទសំបូរ ប្រាង្គ N7 (មើលពីមុខខាងជើង)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៣៖ ប្រាសាទសំបូរ ប្រាង្គ N7 (មើលពីមុខពាយព្យ)



រូបលេខ៤៖ ប្រាសាទសំបូរ ប្រាង្គ N7 (មើលពីមុខនិរតី)

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ៥៖ ផ្នែកដំបូលខាងក្នុង នៃប្រាសាទសំបូរ ប្រាង្គ N7



រូបលេខ៦៖ ជើងទម្រងមូលនៅក្នុងគភ៌គ្រឹះប្រាសាទសំបូរ ប្រាង្គ N7

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៧៖ ជើងទម្រពង់ប្រាំបីជ្រុងនៅខាងមុខប្រាសាទសំបូរ ប្រាង្គ N7



រូបលេខ៨៖ ផ្តែរទ្វារច្រកចូលខាងកើតនៃប្រាសាទសំបូរ ប្រាង្គ N7

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៩៖ ចម្លាក់វិមានអណ្តែតនៅលើជញ្ជាំងប្រាសាទសំបូរ ប្រាង្គ N7

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១០៖ ចម្លាក់វិមានអណ្តែតនៅលើជញ្ជាំងប្រាសាទសំបូរ ប្រាង្គ N7

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១១៖ ចម្លាក់វិមានអណ្តែតនៅលើជញ្ជាំងប្រាសាទសំបូរ ប្រាង្គ N7

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១២៖ ចម្លាក់វិមានអណ្តែតនៅលើជញ្ជាំងប្រាសាទសំបូរ ប្រាង្គ N7

អត្ថបទដោយ៖ ម៉ង់ វ៉ាលី